# ការផ្លាយប្រេងនៅក្នុងតំបន់ឈូងសមុទ្របាយការណ៍ពីការទូទាត់ប្រាក់សំណង ទៅលើប្រាក់ចំណូលផ្សេងទៀត សម្រាប់ប្រើប្រាស់នៅក្នុងការរៀបចំទម្រង់ប្រាក់ពន្ធដែលត្រូវបង់នៃឆ្នាំ 2010

**សំណួរ។ តើខ្ញុំបង់បន្ថែមទៅក្នុងទម្រង់ទូទាត់ប្រាក់ពន្ធសហព័ន្ធ (ទម្រង់ 1040) សម្រាប់ការខាតបង់ប្រាក់ចំណូល ឬប្រាក់ចំណេញដែលបានរាយការណ៍មកខ្ញុំនៅលើទម្រង់ 1099-MISC ឆ្នាំ 2010 ក្នុងប្រអប់ 3 ដូចម្តេចដែរ?**

ប្រសិនបើលោកអ្នកទទួលបានការទូទាត់ប្រាក់សំណងជំនួសអោយប្រាក់ចំណូល ឬប្រាក់ចំណេញដែលលោកអ្នកបានខាតបង់ក្នុងនាមជានិយោជិក បូកបន្ថែមចំនួនទឹកប្រាក់នៃការទូទាត់ទាំងនោះពីទម្រង់ 1099-MISCប្រអប់ 3 នៅលើទម្រង់ទូទាត់ប្រាក់ពន្ធសហព័ន្ធ ទម្រង់ 1040 បន្ទាត់ទី 21។

ប្រសិនបើលោកអ្នកទទួលបានការទូទាត់ប្រាក់សំណងជំនួសអោយប្រាក់ចំណូល ឬប្រាក់ចំណេញដែលលោកអ្នកបានខាតបង់ក្នុងនាមជាអ្នកប្រកបរបរដោយខ្លួនឯង បូកបន្ថែមចំនួនទឹកប្រាក់នៃការទូទាត់ទាំងនោះពីទម្រង់ 1099-MISCប្រអប់ 3 នៅលើទម្រង់ទូទាត់ប្រាក់ពន្ធសហព័ន្ធ ទម្រង់ 1040 បន្ទាត់ទី 1 ឬទម្រង់ 1040 កំណត់ពេលវេលា C-EZ បន្ទាត់ទី 1។ ប្រាក់ចំណេញឬ ប្រាក់ខាតបង់មកពីទម្រង់កំណត់ពេលវេលា C ឬ ទម្រង់កំណត់ពេលវេលា C-EZ របស់លោកអ្នក ត្រូវ បានរាប់បញ្ចូលនៅលើទម្រង់ 1040 កំណត់ពេលវេលា SE។

កំណត់សំគាល់: លោកអ្នកអាចទទួលបានការទូទាត់ប្រាក់សំណងទៅតាមហេតុផល ក្រៅពីជំនួសប្រាក់ចំណូល ឬប្រាក់ចំណេញដែលខាតបង់ ដែលការទូទាត់នេះត្រូវបានរាយការណ៍ទៅលោកអ្នកតាមទម្រង់1099-MISC ប្រអប់ 3។ ចំនួនទឹកប្រាក់ដែលត្រូវបានទូទាត់សម្រាប់ការរងរបួសរាងកាយបុគ្គល ជំងឺប្រចាំកាយ ឬការខូតខាតទ្រព្យសម្បត្តិ អាចមិនទាមទារអោយបង់ពន្ធ ហើយអាចមិនតម្រូវអោយរាយការណ៍នៅលើទម្រង់ទូទាត់ប្រាក់ពន្ធសហព័ន្ធ ទេ។ សម្រាប់ការណែនាំពីការទូទាត់បន្ថែមនៅលើទម្រង់1040 ក្រៅពីចំនួនទឹកប្រាក់ដែលបានរាយ

ការណ៍ទៅ លោកអ្នកនៅលើទម្រង់1099-MISC ក្នុងប្រអប់៤ឬ នៅក្នុងប្រអប់ផ្សេងនៅលើទម្រង់1099-MISC សូមមើលសេចក្តីណែនាំនៅលើទម្រង់1040។

## សំណួរ។ តើខ្ញុំអាចទាក់ទងទៅអ្នកណា ប្រសិនបើខ្ញុំត្រូវការជំនួយបន្ថែម

សម្រាប់សំនួរចំលើយបន្ថែមដែលពាក់ពន្ធទៅនឹងការយោគយល់ក្នុងការទូទាត់ពន្ធ ដែលទទួលបានពីការគណនាទៅលើការធ្លាយប្រេងដែលអាចរកមើលបាននៅលើគេហទំព័រ www.irs.gov។ ប្រភេទនៃ "ការធ្លាយប្រេង នៅក្នុងតំបន់ឈូងសមុទ្រក្នុងប្រអប់ស្វែងរក។ សំណួរបន្ថែមអាចត្រូវបានផ្តល់ជាចម្លើយតាមរយះការហៅទូរស័ព្ទទៅ IRS តាមរយះលេខ 1-866-562-5227។

**បុគ្គលម្នាក់ៗមានស្ថានភាពហិរញ្ញវត្ថុប្លែកៗពីគ្នា** IRS លើកទឹកចិត្តអ្នកបង់ពន្ធទាំងអស់អោយពិនិត្យមើលស្ថានភាពពន្ធរបស់ពួកគេ ឬពិគ្រោះជាមួយអ្នករៀបចំពន្ធដារសម្រាប់ពួកគេអំពីករណីជំពាក់ជំពិនក្នុងការទូទាត់ប្រាក់សំណង ឬប្រាក់សំណងបន្ថែមពីការការធ្លាយប្រេង។

សេវាកម្មគាំទ្រអ្នកបង់ពន្ធ (TAS) គឺជាអង្គការឯករាជ្យមួយចំណុះអោយ IRS។ TAS ជួយអ្នកបង់ពន្ធដែលកំពុងឆ្លងកាត់នូវការលំបាកខាងសេដ្ឋកិច្ច អ្នកបង់ពន្ធ ដែលកំពុងស្វែងរកជំនួយដោះស្រាយបញ្ហាជាមួយនឹង IRS ហើយអ្នកទាំងនោះដែកជាអ្នកជឿជាក់ថាប្រព័ន្ធ ឬបែបបទរបស់ IRS មិនធ្វើការទៅតាមអ្វីដែលគេគួរតែធ្វើទេ។ ប្រសិនបើលោកអ្នកជឿជាក់ថាលោកអ្នកទទួលបានជំនួយពី TAS លោកអ្នកអាចទាក់ទង TAS តាមរយះការហៅទូរស័ព្ទដោយឥតគិតថ្លៃមកលេខ 1-877-777-4778 ឬអ្នកមានបញ្ហាខាងសោតវិញ្ញាណ(TTY/TDD) សូមហៅមកលេខ 1-800-829-4059។ សម្រាប់ព័ត៌មានបន្ថែម
សូមចូលទៅគេហទំព័រwww.irs.gov/advocate។